ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣

ក្រសួងសាធារណការ និងដឹកជញ្ជូន
លេខ: ០២៩ សក.ប្រក

# ប្រកាស
## ស្តីពី
## នីតិវិធីនៃការផ្លាក ឬការដេកហូតអាជ្ញាបណ្ណផ្លូវថ្នល់

## រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៤/០០៨ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីផ្លូវថ្នល់
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ២២០ អនក្រ.បក ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការដំឡើងនាយកដ្ឋានសំណង់ប្រព័ន្ធចម្រោះទឹកកខ្វក់ ទៅជាអគ្គនាយកដ្ឋានប្រព័ន្ធចម្រោះទឹកកខ្វក់ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២១ ស្តីពីការប្រែក្លាយនិងដំឡើងវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេសសាធារណការ និងដឹកជញ្ជូន ទៅជាវិទ្យាស្ថានតេជោសែនសាធារណការ និងដឹកជញ្ជូន របស់ក្រសួងសាធារណការនិងដឹកជញ្ជូន

- បានឃើញអនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការដំឡើងនាយកដ្ឋានព័ត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈ ទៅជាអគ្គនាយកដ្ឋានបច្ចេកវិទ្យា និងទំនាក់ទំនងសាធារណៈ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការស្នើសុំអាជ្ញាបណ្ណប្រកបអាជីវកម្មលើវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ការថែទាំផ្លូវថ្នល់ និងការបើកមន្ទីរពិសោធន៍វិស័យផ្លូវថ្នល់
- យោងប្រកាសលេខ ៧១២ ប្រក.សក. ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការស្នើសុំចុះបញ្ជីនិងការស្នើសុំអាជ្ញាបណ្ណផ្លូវថ្នល់របស់អង្គភាពរដ្ឋដែលអនុវត្តការងារពាក់ព័ន្ធនឹងវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់
- យោងប្រកាសលេខ ២១៤ ប្រក.សក. ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីទម្រង់បែបបទ គំរូពាក្យស្នើសុំអាជ្ញាបណ្ណ និងគំរូអាជ្ញាបណ្ណផ្លូវថ្នល់
- យោងប្រកាសលេខ ២១៥ ប្រក.សក. ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការធ្វើបុរេគុណវុឌ្ឍិ និងការធ្វើចំណាត់ថ្នាក់បុគ្គលដែលស្នើសុំអាជ្ញាបណ្ណផ្លូវថ្នល់
- ប្រកាសលេខ០២៨...ប្រក.សក ចុះថ្ងៃទី២៥...ខែ.កុម្ភៈ..ឆ្នាំ២០២៥...ស្តីពីនីតិវិធីនៃការពិនិត្យ និងការវាយតម្លៃ ដើម្បីផ្តល់អាជ្ញាបណ្ណ បន្តអាជ្ញាបណ្ណ ផ្ទេរឈ្មោះអ្នកកាន់អាជ្ញាបណ្ណ និងបដិសេធមិនផ្តល់អាជ្ញាបណ្ណផ្លូវថ្នល់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសាធារណការ និងដឹកជញ្ជូន

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះកំណត់អំពីនីតិវិធីនៃការផ្អាក ឬការដកហូតអាជ្ញាបណ្ណផ្លូវថ្នល់ពីបុគ្គល និងអង្គភាពរដ្ឋដែលទទួលបានអាជ្ញាបណ្ណផ្លូវថ្នល់ ក្នុងគោលបំណងអនុវត្តអនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការស្នើសុំអាជ្ញាបណ្ណប្រកបអាជីវកម្មលើវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ការថែទាំផ្លូវថ្នល់ និងការបើកមន្ទីរពិសោធន៍វិស័យផ្លូវថ្នល់។

**ប្រការ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះអង្គភាពរដ្ឋដែលអនុវត្តការងារពាក់ព័ន្ធនឹងវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងបុគ្គលដែលប្រកបអាជីវកម្មពាក់ព័ន្ធនឹងវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ការថែទាំផ្លូវថ្នល់ ការផ្តល់សេវាទីប្រឹក្សាបច្ចេកទេសសំណង់ផ្លូវថ្នល់ ការសិក្សាគម្រោងប្លង់ ការត្រួតពិនិត្យសំណង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងការបើកមន្ទីរពិសោធន៍វិស័យផ្លូវថ្នល់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣.-**

វាក្យសព្ទបច្ចេកទេសសំខាន់ៗដែលប្រើក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

**អាជ្ញាបណ្ណផ្លូវថ្នល់** ហៅថាអាជ្ញាបណ្ណ សំដៅដល់លិខិតអនុញ្ញាតប្រកបអាជីវកម្មលើវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ថែទាំផ្លូវថ្នល់ ផ្តល់សេវាទីប្រឹក្សាបច្ចេកទេសសំណង់ផ្លូវថ្នល់ សិក្សាគម្រោងប្លង់ ត្រួតពិនិត្យសំណង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងបើកមន្ទីរពិសោធន៍វិស័យផ្លូវថ្នល់។

បុគ្គល សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលប្រកបអាជីវកម្មលើវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ថែទាំផ្លូវថ្នល់ ផ្តល់សេវាទីប្រឹក្សាបច្ចេកទេសសំណង់ផ្លូវថ្នល់ សិក្សាគម្រោងប្លង់ ត្រួតពិនិត្យសំណង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងបើកមន្ទីរពិសោធន៍វិស័យផ្លូវថ្នល់។

**អង្គភាពរដ្ឋ** សំដៅដល់អង្គភាពកងវិស្វកម្មក្រសួងការពារជាតិ អង្គភាពកងវិស្វកម្មក្រសួងមហាផ្ទៃ និងអង្គភាពរបស់រដ្ឋផ្សេងៗទៀតដែលអនុវត្តការងារពាក់ព័ន្ធនឹងវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់។

## ជំពូកទី២

## នីតិវិធីនៃការផ្អាក ឬដកហូតអាជ្ញាបណ្ណផ្លូវថ្នល់

**ប្រការ៤.-**

ការស៊ើបអង្កេតនឹងត្រូវបានធ្វើឡើងចំពោះបុគ្គល ឬអង្គភាពរដ្ឋដែលអនុវត្តគម្រោងពាក់ព័ន្ធនឹងវិស័យផ្លូវថ្នល់ បន្ទាប់ពីទទួលបានរបាយការណ៍ពីទីប្រឹក្សាបច្ចេកទេសប្រចាំគម្រោង និង/ឬក្រុមត្រួតពិនិត្យបច្ចេកទេសក្រសួង។

ក្នុងករណីបុគ្គល ឬអង្គភាពរដ្ឋដែលអនុវត្តគម្រោងពាក់ព័ន្ធនឹងវិស័យផ្លូវថ្នល់ មិនអនុវត្តតាមកិច្ចសន្យាសាងសង់ ឬបទប្បញ្ញត្តិបច្ចេកទេស មន្ត្រីអធិការកិច្ចផ្លូវថ្នល់មានសមត្ថកិច្ចត្រូវសិក្សាស្រាវជ្រាវនិងលើកសំណើជូនរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីចេញលិខិតព្រមានជាលាយលក្ខណ៍អក្សរ។

ក្នុងករណីបុគ្គល ឬអង្គភាពរដ្ឋមិនអនុវត្តតាមលិខិតព្រមានដូចបានលើកឡើងក្នុងកថាខណ្ឌទី២ខាងលើ ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃគិតចាប់ពីថ្ងៃចេញលិខិតព្រមាន មន្ត្រីអធិការកិច្ចផ្លូវថ្នល់មានសមត្ថកិច្ច ត្រូវពិនិត្យរៀបចំលើកសំណើជូនរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីពិនិត្យនិងចេញសេចក្តីសម្រេចផ្អាកអាជ្ញាបណ្ណផ្លូវថ្នល់។

**ប្រការ៥.-**

ដោយឡែក ការផ្អាកអាជ្ញាបណ្ណផ្លូវថ្នល់ត្រូវធ្វើឡើងចំពោះបុគ្គល ឬអង្គភាពរដ្ឋ ក្នុងករណីណាមួយដូចខាងក្រោម៖

១-វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មត្រូវបានព្យួរ

២-ការជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការស្នើសុំផ្អាកការប្រកបអាជីវកម្មរបស់ខ្លួន

៣-ការមិនស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណផ្លូវថ្នល់ ក្នុងរយៈពេលលើសពី ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃ ដែលអាជ្ញាបណ្ណផ្លូវថ្នល់ផុតសុពលភាព

៤-ការផ្លាស់ប្តូររចនាសម្ព័ន្ធដោយមិនគោរពតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា៩ និងមាត្រា១៦ នៃអនុក្រឹត្យ លេខ ៩៤ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការស្នើសុំអាជ្ញាបណ្ណប្រកបអាជីវកម្មលើវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ការថែទាំផ្លូវថ្នល់ និងការបើកមន្ទីរពិសោធន៍វិស័យផ្លូវថ្នល់

៥-ការផ្ទេរសិទ្ធិកាន់កាប់អាជ្ញាបណ្ណផ្លូវថ្នល់ឱ្យបុគ្គលដទៃ ឬសហព័ទ្ធ ឬកូន ឬអ្នកតំណាងស្របច្បាប់ ដើម្បីទទួលខុសត្រូវជំនួស ដោយគ្មានការអនុញ្ញាតជាមុនពីក្រសួងសាធារណការ និងដឹកជញ្ជូនជាលាយលក្ខណ៍អក្សរ

៦-ការមិនព្រមសហការជាមួយមន្ត្រីអធិការកិច្ចផ្លូវថ្នល់ ឬក្រុមបច្ចេកទេសជំនាញក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលបំពេញភារកិច្ចចុះត្រួតពិនិត្យ និង/ឬធ្វើអធិការកិច្ចនៃការអនុវត្តកិច្ចសន្យាពាក់ព័ន្ធនឹងវិស័យផ្លូវថ្នល់

៧-ការទទួលបានសាលក្រម ឬសាលដីកា បង្គាប់ឱ្យផ្អាកសកម្មភាពបណ្ដោះអាសន្ន។

**ប្រការ៦.-**

រយៈពេលនៃការផ្អាកអាជ្ញាបណ្ណផ្លូវថ្នល់ដូចមានចែងក្នុងកថាខណ្ឌទី៣នៃប្រការ៤ និងចំណុចទី៣ ទី៤ ទី៥ ឬទី៦ នៃប្រការ៥នៃប្រកាសនេះ មិនត្រូវឱ្យលើសពី ៣ (បី) ខែ គិតចាប់ពីថ្ងៃចេញសេចក្ដីសម្រេចនៃការផ្អាកអាជ្ញាបណ្ណផ្លូវថ្នល់។ រយៈពេលនៃការផ្អាកអាជ្ញាបណ្ណផ្លូវថ្នល់នេះត្រូវគិតបញ្ចូលទាំងសុពលភាពនៃអាជ្ញាបណ្ណផ្លូវថ្នល់ផងដែរ។

ក្រសួងសាធារណការ និងដឹកជញ្ជូន អាចចេញសេចក្ដីណែនាំ ឬបទបញ្ជាជាក់លាក់ទៅបុគ្គល ឬអង្គភាពរដ្ឋ ដែលទទួលរងការផ្អាកអាជ្ញាបណ្ណផ្លូវថ្នល់ ឱ្យធ្វើការកែតម្រូវឡើងវិញ ក្នុងអំឡុងពេលនៃការផ្អាកអាជ្ញាបណ្ណផ្លូវថ្នល់។

អាជ្ញាបណ្ណផ្លូវថ្នល់ដែលត្រូវបានផ្អាក នឹងត្រូវប្រគល់ទៅបុគ្គល ឬអង្គភាពរដ្ឋ ដែលជាម្ចាស់អាជ្ញាបណ្ណវិញ បន្ទាប់ពីបុគ្គល ឬអង្គភាពរដ្ឋនោះ បានបំពេញយ៉ាងពេញលេញនិងត្រឹមត្រូវតាមលក្ខខណ្ឌតម្រូវនៃសេចក្ដីណែនាំ ឬ បទបញ្ជារបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

**ប្រការ៧.-**

រយៈពេលនៃការផ្អាកអាជ្ញាបណ្ណផ្លូវថ្នល់ដូចមានចែងក្នុងចំណុចទី១ ទី២ ឬទី៧ នៃប្រការ៥នៃប្រកាសនេះ មិនត្រូវឱ្យលើសពី ១ (មួយ) ឆ្នាំ គិតចាប់ពីថ្ងៃចេញសេចក្ដីសម្រេចនៃការផ្អាកអាជ្ញាបណ្ណផ្លូវថ្នល់។ រយៈពេលនៃការផ្អាកអាជ្ញាបណ្ណផ្លូវថ្នល់នេះត្រូវគិតបញ្ចូលទាំងសុពលភាពនៃអាជ្ញាបណ្ណផ្លូវថ្នល់ផងដែរ។

បុគ្គល ឬអង្គភាពរដ្ឋ ត្រូវរៀបចំដំណើរការ ឬទទួលវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ឬទទួលបានសេចក្ដីសម្រេចឱ្យប្រកបអាជីវកម្មពីតុលាការវិញ ក្នុងរយៈពេលដូចបានកំណត់ក្នុងកថាខណ្ឌទី១ខាងលើ។

អាជ្ញាបណ្ណផ្លូវថ្នល់ដែលត្រូវបានផ្អាក នឹងត្រូវប្រគល់ទៅបុគ្គល ឬអង្គភាពរដ្ឋ ដែលជាម្ចាស់អាជ្ញាបណ្ណវិញ បន្ទាប់ពីបុគ្គល ឬអង្គភាពរដ្ឋនោះ បានជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងសាធារណការនិងដឹកជញ្ជូន ពីដំណើរការនៃការប្រកបអាជីវកម្មឡើងវិញ ឬការទទួលវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មវិញ ឬការទទួលបានសេចក្ដីសម្រេចឱ្យប្រកបអាជីវកម្មពីតុលាការវិញ។

**ប្រការ៨.-**

ការដកហូតអាជ្ញាបណ្ណផ្លូវថ្នល់ត្រូវធ្វើឡើងចំពោះបុគ្គល ឬអង្គភាពរដ្ឋ ក្នុងករណីណាមួយដូចខាងក្រោម៖

១-មិនពិនិត្យកែសម្រួលតាមលិខិតព្រមានក្នុងរយៈពេល ៣ (បី) ខែ គិតចាប់ពីថ្ងៃដែលអាជ្ញាបណ្ណផ្លូវថ្នល់ ត្រូវបានផ្អាក ដូចបានកំណត់ក្នុងកថាខណ្ឌទី១នៃប្រការ៦នៃប្រកាសនេះ

២-នៅតែបន្តបំពានលក្ខខណ្ឌដូចមានក្នុងចំណុចទី៣ ទី៤ ទី៥ ឬទី៦ នៃប្រការ៥នៃប្រកាសនេះ

៣-នៅតែមិនអាចបន្តការប្រកបអាជីវកម្ម ឬមិនអាចទទួលបានវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ឬមិនអាចទទួលបានសេចក្ដីសម្រេចឱ្យប្រកបអាជីវកម្មពីតុលាការ ក្នុងរយៈពេល ១ (មួយ) ឆ្នាំ

៤-បានជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបញ្ចប់ការប្រកបអាជីវកម្មរបស់ខ្លួន

៥-ត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម

៦-ត្រូវបានរកឃើញថាបានប្រព្រឹត្តល្មើសនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន

៧-ត្រូវបានតុលាការចេញសេចក្តីសម្រេចដកហូតសិទ្ធិឬហាមឃាត់ការប្រកបអាជីវកម្ម ឬបង្គាប់ឱ្យរំលាយ។

**ប្រការ៩ .-**

បុគ្គល ឬអង្គភាពរដ្ឋ ដែលត្រូវបានដកហូតអាជ្ញាបណ្ណផ្លូវថ្នល់ អាចស្នើសុំអាជ្ញាបណ្ណផ្លូវថ្នល់ជាថ្មី ក្រោយរយៈពេល ០៥ (ប្រាំ) ឆ្នាំ គិតចាប់ពីថ្ងៃដកហូតអាជ្ញាបណ្ណផ្លូវថ្នល់ និងត្រូវអនុវត្តតាមអនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការស្នើសុំអាជ្ញាបណ្ណប្រកបអាជីវកម្មលើវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ការថែទាំផ្លូវថ្នល់និងការបើកមន្ទីរពិសោធន៍វិស័យផ្លូវថ្នល់។

## ជំពូកទី៣
## ការប្តឹងតវ៉ា

**ប្រការ១០ .-**

បុគ្គល ឬអង្គភាពរដ្ឋ ដែលរងការផ្អាក ឬដកហូតអាជ្ញាបណ្ណផ្លូវថ្នល់ មានសិទ្ធិប្តឹងតវ៉ា ស្របតាមមាត្រា១៥ នៃអនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការស្នើសុំអាជ្ញាបណ្ណប្រកបអាជីវកម្មលើវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ការថែទាំផ្លូវថ្នល់ និងការបើកមន្ទីរពិសោធន៍វិស័យផ្លូវថ្នល់។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**ប្រការ១១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១២ .-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកវិទ្យាស្ថានតេជោសែនសាធារណការនិងដឹកជញ្ជូន ប្រធានមន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានី ខេត្ត និងប្រធានអង្គភាពក្រោមឱវាទក្រសួង ត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារ នៃប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ...ចន្ទ ១៣ កើត...ខែ...ស្រាពណ៍...ឆ្នាំ...ម្សាញ់...សប្តស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...២៥...ខែ...កក្កដា...ឆ្នាំ២០២៥

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ប៉េង ពោធិ៍នា**

**កន្លែងទទួល ៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ ១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ